អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

# បុណ្យភ្ជុំបិណ្ឌ



សូមស្កេនQR Code

គំនូរជីវចល    ធនធានបង្រៀន

និពន្ធដោយ៖ ផាត លក្ខិណា

រូបភាពដោយ៖ សែម រ៉ាស៊ីន

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C




ប៉ាសួរ «តើកូនដឹងទេថា ខែនេះមានពិធីបុណ្យអ្វី?»

«ចាសប៉ា! ពិធីបុណ្យភ្ជុំបិណ្ឌ ដែលមានរយៈពេល១៥ថ្ងៃ ជាពិធីបុណ្យនឹករលឹកសាច់ញាតិ ដែលបានស្លាប់របស់ជនជាតិខ្មែរ រៀងរាល់មួយឆ្នាំម្តង» វ៉ាណាឆ្លើយ។

«ចុះហេតុអ្វីបានជាកូនដឹង?» ប៉ាបន្តសួរ។



«អូ! តើកូនបានដឹងអ្វីផ្សេងទៀតដែរឬទេ អំពីពិធីបុណ្យភ្ជុំបិណ្ឌ?»

«អត់ទេប៉ា! អ្នកគ្រូបង្រៀនកូនតែប៉ុណ្ណឹង»។

«បាទកូន! អីចឹងចាំប៉ារៀបរាប់ឱ្យកូនស្ដាប់។

ពិធីបុណ្យភ្ជុំបិណ្ឌគេប្រារព្ធធ្វើចាប់ពីថ្ងៃទី១រោច ដល់ថ្ងៃទី១៤រោច ខែភទ្របទ។ អ្នកភូមិនាំគ្នាដាក់បិណ្ឌ ឬ កាន់បិណ្ឌ រីឯថ្ងៃទី១៥រោចគេហៅថា ភ្ជុំបិណ្ឌ។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



ពិធីបុណ្យភ្ជុំបិណ្ឌសំខាន់ៗមានដូចជា ពិធីសូត្រមន្ត បង្សុកូល បោះបាយបិណ្ឌ ពិធីបំបួសភ្នំខ្សាច់ និងពិធីសែនលាដូនតាជាដើម។



មនុស្សម្នាច្រើនកុះករយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅឯវត្តមានដូចជា ម្ហូបអាហារ ផ្លែឈើ នំចំណីនិងគ្រឿងសក្ការៈបូជា។



ហើយគេតែងតែផចនំខ្មែរមានដូចជា នំអន្សមជ្រូក នំអន្សមចេក នំគម នំបត់និងនំជាច្រើនមុខផ្សេងទៀត ព្រោះជាទំនៀមទម្លាប់ប្រពៃណីជាតិ»។

«មែនហើយប៉ា កូនចង់ចេះផចនំអន្សមជ្រូក ប៉ុន្តែគ្មាននរណាបង្រៀនកូនសោះ»។













«តើការធ្វើនំអន្សមជ្រូកត្រូវការគ្រឿងផ្សំអ្វីខ្លះដែរប៉ា?»

«បាទកូន! មានដូចជា អង្ករដំណើប សណ្តែកបាយ សាច់ជ្រូក ដូង ស្លឹកចេកនិងខ្សែចំណង»។



«ចុះរបៀបវេចនំអន្សមជ្រូកវិញ?»

«បាទកូន! ដំបូងកាត់ស្លឹកចេកហាលឱ្យស្រពាប់បន្តិច កាត់ខ្សែចំណងល្មមចង
រួចយកអង្ករដំណើបឆាជាមួយដូងឱ្យមានក្លិនឈ្ងុយ។
បន្ទាប់មក ស្ងោរសណ្ដែកបាយឱ្យផុយ សាច់ជ្រូកហាន់ជាចង្វាមូលល្មមសមគួរ ប្រឡាក់អំបិល ម្រេច ស្ករនិងខ្ទឹម។

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C







តម្រៀបស្លឹកចេកដាក់អង្ករដំណើប ដាក់សណ្ដែកបាយពីលើ រួចដាក់សាច់ជ្រូក
ហើយចងឱ្យស្អាត ដើម្បីស្ងោរកុំឱ្យទឹកចូល ព្រោះវាអាចបែកខូចនំ។
ចំណែករបៀបស្ងោរវិញ យកស្លឹកចេកដាក់នៅបាតឆ្នាំងជាមុនសិន ទើបដាក់នំចូលក្នុងឆ្នាំង ស្ងោរឱ្យពុះខ្លាំង។
ពេលស្រង់នំចេញព្យួរឱ្យខ្សោះទឹក»។



«មុនថ្ងៃភ្ជុំបិណ្ឌ ប៉ានឹងបង្រៀនកូនធ្វើនំអន្សមជ្រូក ដើម្បីកុំឱ្យបាត់បង់ប្រពៃណីជាតិខ្មែរ»។
«ចាសប៉ា! តើប៉ាចេះធ្វើនំអន្សមដែរឬទេ?»
«បាទ ប៉ាចេះតើកូន! យាយទួតរបស់កូនគឺជាអ្នកលក់នំខ្មែរនៅឯខេត្តបាត់ដំបង
កាលពីក្មេងប៉ាតែងតែជួយយាយទួតធ្វើនំលក់»។



រ៉ាណាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង!

នាងលាន់មាត់ថា «ប៉ាពិតជាអស្ចារ្យណាស់!

នៅពេលកូនចេះវេចនំអន្សមជ្រូក កូននឹងរៀនធ្វើនំផ្សេងៗទៀត

ហើយកូននឹងបង្រៀនអ្នកជិនាន់ក្រោយបន្ត ដើម្បីកុំឱ្យបាត់បង់ប្រពៃណីជាតិខ្មែរយើង»។